ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

៣០-១២-២០០៥ -ព្រះរាជក្រម នស/រកម/១២០៥/០៤០ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៦ ០១

២_ព្រះរាជក្រឹត្យ

១៧-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៤ ស្តីពីការតែងតាំង ឯកឧត្តមចំនួន ០៥ រូប ជាឧបការីសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៣៨

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៨ ស្តីពីការតែងតាំង លោក **ឡោ ហ៊ិតស៊ុយ** ជា ឧកញ៉ា ៣៩

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥០៩ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ុំ ហឿន** ជាទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤០

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៤ ស្តីពីការតែងតាំង អ្នកអង្គម្ចាស់ **នរោត្តម ពុទ្ធពង្ស** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៤១

២២-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥១៥ ស្តីពីការតែងតាំង ឯកឧត្តម **ឆេង ម៉ុន្នា** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកផ្នែកសង្គមកិច្ច និងមនុស្សធម៌ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្ស ៤២

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២១ ស្តីពីការកែសម្រួលថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ១១ រូប និងត្រូវបានតម្លើងឋានន្តរស័ក្តិពី វរមន្ត្រី ទៅ ឧត្តមមន្ត្រី ក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ០៤រូប ៤៣

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២២ ស្តីពីការផ្ទេរក្របខ័ណ្ឌ លោក **ភាន រិទ្ធី** អនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍ ឱ្យទៅបំរើការងារជាអនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៤៥

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៣ ស្តីពីការប្រគល់ភារកិច្ចជូនឯកឧត្តម **សេង យូអ៊ាន់** ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៦

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៤ ស្តីពីការតែងតាំងឯកឧត្តម **ឡាយ ទីសា** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៧

២៨-១២-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/១២០៥/៥២៥ ស្តីពីការតែងតាំងលោកជំទាវ **អ៊ុក ម៉ាលី** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤៨

II.រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៤-០១-២០០៦ -អនុក្រឹត្យលេខ ០១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៤៩

០៤-០១-២០០៦ -អនុក្រឹត្យលេខ ០២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៣

III.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-០១-២០០៦ -ប្រកាសលេខ ០០២ សហវ.ប្រក ស្តីពីលតាប័ត្រធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច ៥៤

២.ទីស្តីការរដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

០៣-០១-២០០៦ -ប្រកាសលេខ ០០១ ប្រក/០៦ ក.ក.ប.វ ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សូស្យល អ៊ិមផ្លយមេន អេជេនស៊ី(Social Employment Agency.)ធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និង គ្រប់គ្រងពលករកម្ពុជាទៅធ្វើការ នៅព្រះរាជាណាចក្រថៃឡង់ដ៍ ប្រទេសម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ និងបញ្ជូនសិក្ខាកាមកម្ពុជាទៅបណ្តុះបណ្តាលជំនាញនៅប្រទេសជប៉ុន ៥៧

៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០២-១១-២០០៥ -លិខិតលេខ ២៤៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យ៉ាកជីន (ខេមបូឌា) អ៊ីន** ៥៩

១១-១១-២០០៥ -លិខិតលេខ ២៥៤៨ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **ខូត ហ្វុខ ហ៊្វូ** " ប្រចាំរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ៦០

១១-១១-២០០៥ -លិខិតលេខ ២៥៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ម៉ាលីស ខូ អិលធីឌី** ៦១

១៤-១១-២០០៥ -លិខិតលេខ ២៥៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ឡូចជីញ អេស.អេ** ៦៣

១៤-១១-២០០៥ -លិខិតលេខ ២៥៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហេខ ហ្វូដ** ៦៤

១៤-១១-២០០៥ -លិខិតលេខ ២៥៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឆូសែខូ ខាហ្គោ ត្រេនស្ព័រ ថេសិន គ្រុប** ៦៦

១៨-១១-២០០៥ -លិខិតលេខ ២៦០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ត្រេន ត្រាវែល** ៦៨

១៨-១១-២០០៥ -លិខិតលេខ ២៦០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អិម ធី អិន ខនសេប** ៧០

២៣-១១-២០០៥ -លិខិតលេខ ២៦២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន**(ខេមបូឌា) ហ្វុខម៉ី អ៊ីម & អេច** ៧២

២៨-១១-២០០៥ -លិខិតលេខ ២៦៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គល ពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ស៊ី.អេ អ៊ិនជីនារីខ ខូ អិលធីឌី** ៧៣

១៤-១២-២០០៥ -លិខិតលេខ ២៧៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន**ធនាគារ ឯកទេស ភ្នំពេញ** ៧៥

ព្រះរាជក្រម

នស/រកម/១២០៥/០៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ជំពូកទី ១

ចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

មាត្រា ១.-

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ២០០៦ ឱ្យប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុន និង ចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវអំណោយ មូលនិធិបដិភាគ និង ធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង “ក” ដែលភ្ជាប់មកជាមួយច្បាប់នេះក្នុងទឹកប្រាក់សរុបចំនួន ៣.៨១៤.១២៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណូលចរន្ត.......................................២.៧៤០.៧២០ លានរៀល

-ចំណូលជាមូលធន...............................១.០៧៣.៤០៥ លានរៀល

+ ចំណូលជាមូលធនក្នុងប្រទេស...................៧២.០០០ លានរៀល

+ ចំណូលជាមូលធនក្រៅប្រទេស.............១.០០១.៤០៥ លានរៀល

មាត្រា ២.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានសម្រាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានកំណត់ស្មើនឹង ៣.៨១៤.១២៥ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ :

-ចំណាយចរន្ត.......................................២.៤១៤.២៥៥ លានរៀល

-ចំណាយជាមូលធន...............................១.៣៩៩.៨៧០ លានរៀល

+ ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស...៤៤៥.៩៨០ លានរៀល

+ ដោយមូលនិធិថវិកា[១] ....៣០២.៣៧៥ លានរៀល

+ ដោយមូលនិធិក្រៅប្រទេសដែលអ្នកផ្ដល់អំណោយបានយល់ព្រមជាមុន.. ....១៤៣.៦០៥ លានរៀល

---

(១) រួមមានចំណាយសាងសង់ និង ទិញសម្ភារៈ ១៨៣.៥៧៥ លានរៀល និង ចំណាយបដិភាគ ១១៨.៨០១ លានរៀល

(២) វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ហើយចំនួនទឹកប្រាក់នេះមិនឆ្លងកាត់រតនាគារទេ ។

+ ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលអនុវត្តក្រៅរតនាគារជាតិ[២] ....៨៥៧.៨០០ លានរៀល

+ ចំណាយរំលស់បំណុល.............................៩៦.០៩០ លានរៀល

មាត្រា ៣.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានថវិកាសម្រាប់ចំណាយចរន្តរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានកំណត់ស្មើនឹង ២.៤១៤.២៥៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទនៃថវិកា ដូចមានចែងក្នុងតារាង “ខ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៤.-

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋសម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០០៦ ដល់ ២០០៨ ត្រូវបានកំណត់ស្មើនឹង ៥.៤១៧.៧០៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង “$គ_១$-$គ_២$-$គ_៣$” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៥.-

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និង ឥណទានទូទាត់សម្រាប់ចំណាយជាមូលធននៃថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានកំណត់ដូចតទៅ :

-ឥណទានភ្ជាប់សន្យា.............................១.៧៧៨.០៧០ លានរៀល

-ឥណទានទូទាត់..................................១.៣៩៩.៨៧០ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស :

-ឥណទានភ្ជាប់សន្យា..............................៤៤៥.៩៨០ លានរៀល

-ឥណទានទូទាត់....................................៤៤៥.៩៨០ លានរៀល

ខ.វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ :

-ឥណទានភ្ជាប់សន្យា...........................១.២៣៦.០០០ លានរៀល

-ឥណទានទូទាត់....................................៨៥៧.៨០០ លានរៀល

គ. ការរំលស់បំណុលសាធារណៈ :

-ឥណទានភ្ជាប់សន្យា................................៩៦.០៩០ លានរៀល

-ឥណទានទូទាត់.......................................៩៦.០៩០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និង តាមស្ថាប័នប្រហាក់ប្រហែល នីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង “ឃ” ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

មាត្រា ៦.-

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលបានរៀបចំឡើង ដោយតារាង “ក” ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋ និង តារាង “ខ” ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ :

ឯកតា:លានរៀល

- កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ	ចំនួនទឹកប្រាក់	ចំនួនលើស(+) /ឱនភាព(-)
I. ចំណូលក្នុងប្រទេស	២.៨១២.៧២០	
១. ចំណូលចរន្ត	២.៧៤០.៧២០	
២. ចំណូលជាមូលធនក្នុងប្រទេស	៧២.០០០	
II. សរុបចំណាយថវិកា	៣.៧១៨.០៣៥	
១. ចំណាយចរន្ត	២.៤១៤.២៥៥	
២. ចំណាយជាមូលធន [២]	១.៣០៣.៧៨០	
- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស	៤៤៥.៩៨០	
+ ដោយមូលនិធិថវិកា	៣០២.៣៧៥	
គំរោងវិនិយោគ (សាងសង់ - ទព្វសំភារ:)	១៨៣.៥៧៥	
បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	១១៨.៨០០	
+ ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ [៣]	១៤៣.៦០៥	
- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៨៥៧.៨០០	
អតិរេកនៃថវិកាចរន្ត (I.១ -II.១)		+៣២៦.៤៦៥
ឱនភាពសរុបនៃថវិកាទូទៅ (I-II)		-៩០៥.៣១៥
III. ហិរញ្ញប្បទាននៃឱនភាព		+៩០៥.៣១៥
១. ហិរញ្ញប្បទានក្រៅប្រទេស		+៩០៥.៣១៥
- ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ		+១៤៣.៦០៥
- ជំនួយគំរោងការ		+៨៥៧.៨០០
- ការរំលស់បំណុល		-៩៦.០៩០
២. ហិរញ្ញប្បទានធនាគារជាតិ		

[២] មិនគិតការរំលស់បំណុល ៩៦.០៩០ លានរៀល ដែលមានកំណត់នៅក្នុងសារប័ព្ទ III (ហិរញ្ញប្បទាននៃឱនភាព)

[៣] គំរោងទាំងអស់ត្រូវសុំការយល់ព្រមចំណាយពីអ្នកផ្តល់ជំនួយជាមុន។

ជំពូកទី ២

ការកំណត់រយៈពេលអានិភាពសម្រាប់លើកលែងពន្ធលើប្រាក់ចំណេញ ដល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

មាត្រា ៧.-

ដោយអនុលោមតាមមាត្រា ១៤ ថ្មី កថាខណ្ឌ ១៤.១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ បានអនុញ្ញាតឱ្យគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបានទូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ។ រយៈពេលលើកលែងពន្ធនេះរួមមាន : រយៈពេលគន្លឹះបូករយៈពេល៣(បី)ឆ្នាំ បូក រយៈពេលអាទិភាព ។ ចំនួនឆ្នាំនៃរយៈពេលអាទិភាពសម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានកំណត់ដូចខាងក្រោម :

-គម្រោងវិនិយោគដែលមានលក្ខណៈជាឧស្សាហកម្មធុនស្រាល រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ៥.០០០.០០០(ប្រាំលាន)ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ០(សូន្យ) ឆ្នាំ ។

• ទុនវិនិយោគពី ៥.០០០.០០០(ប្រាំលាន) ដុល្លាអាមេរិក ដល់២០.០០០.០០០(ម្ភៃលាន) ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

• ទុនវិនិយោគពី ២០.០០០.០០០(ម្ភៃលាន) ដុល្លាអាមេរិក ឡើងទៅ រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

-គម្រោងវិនិយោគដែលមានលក្ខណៈជាឧស្សាហកម្មធុនធ្ងន់ រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ៥០.០០០.០០០(ហាសិបលាន) ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

• ទុនវិនិយោគពី ៥០.០០០.០០០(ហាសិបលាន) ដុល្លាអាមេរិក ឡើងទៅរយៈពេលអាទិភាពកំណត់ស្មើនឹង ៣(បី) ឆ្នាំ ។

- គម្រោងវិនិយោគដែលមានលក្ខណៈជាទេសចរណ៍ រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ០(សូន្យ) ឆ្នាំ ។

• ទុនវិនិយោគពី ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក ឡើងទៅ រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

- គម្រោងវិនិយោគក្នុងវិស័យកសិកម្មដែលមានលក្ខណៈជាដំណាំកសិកម្ម និងកសិឧស្សាហកម្ម រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ដំណាំកសិកម្មរយៈពេលខ្លី រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

• ដំណាំកសិកម្មរយៈពេលវែង និងកសិឧស្សាហកម្ម រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

-គម្រោងវិនិយោគដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក រយៈពេលអាទិភាព កំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

•ទុនវិនិយោគពី ១០.០០០.០០០(ដប់លាន) ដុល្លារអាមេរិក ដល់ ៣០.០០០.០០០ (សាមសិបលាន) ដុល្លារអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

•ទុនវិនិយោគពី ៣០.០០០.០០០(សាមសិបលាន) ដុល្លារអាមេរិក ឡើងទៅ រយៈពេលអាទិភាព កំណត់ស្មើនឹង ៣(បី) ឆ្នាំ ។

ជំពូកទី ៣

ការខ្ចី និង ការធានារបស់រដ្ឋ

មាត្រា ៨.-

អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេមានកម្រិតរហូតដល់២០០.០០០.០០០ S.D.R (ពីររយលានអេសដេអ៊េ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តន៍នៃការខ្ចី និង ការធានានេះ ជូនរដ្ឋសភា និង ព្រឹទ្ធសភា រៀងរាល់ ៦ខែ ម្ដង ។

រាល់ការខ្ចី និង ការធានារបស់រដ្ឋតាមល័ក្ខខ័ណ្ឌពាណិជ្ជកម្មសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៦ ត្រូវបានហាមឃាត់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឱ្យបោះផ្សាយប័ណ្ណរតនាគារក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០.០០០.០០០.០០០៛ (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយនូវតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

មាត្រា ៩.-

មិនអនុញ្ញាតឱ្យក្រសួង ឬ ស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលប័ត្ររយៈពេលវែង មធ្យម ខ្លី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខា ដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀតដែលត្រូវសងបំណុលតាមកាលកំណត់ ឬ តាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និង ល័ក្ខខ័ណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

ជំពូកទី ៤
និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥

មាត្រា ១០.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង បទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះត្រូវបានយល់ព្រមជាគោលការណ៍ផ្ដល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ចំនួនទឹកប្រាក់ ១៦.៩៦៨ លានរៀល :

-សម្រាប់បើកបៀវត្សជូនជនបាត់បង់សមត្ថភាពការងារ ជនពិការ និង និវត្តជន ដែលជាយោធិនវិសាយពីក្រសួងការពារជាតិ របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តសៀមរាប ចំនួនទឹកប្រាក់ ៦.០៦៨ លានរៀល ។

-សម្រាប់ទូទាត់ចំណាយលើការងារចាំបាច់របស់រាជរដ្ឋាភិបាល របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួនទឹកប្រាក់ ៤.៥០០ លានរៀល ។

-សម្រាប់ចំណាយដំណើរការស្ថានទូតថ្មីដែលបានបើករួចហើយនៅក្រុងឡុងដ៍ ប្រ៊ុចសែល និង ប៉ូឡូញ និង ស្ថានអគ្គកុងស៊ុលថ្មីនៅគុនមីញ និង ឆុងឈីញ ចំនួនទឹកប្រាក់ ៦.៤០០ លានរៀល ។

ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្ដែងនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមខាងលើនេះ ។

ជំពូកទី ៥
ថវិការបស់ខេត្ត ក្រុង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦

មាត្រា ១១.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ កញ្ចប់ថវិការួមនៃថវិការបស់ខេត្ត-ក្រុង សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ត្រូវបានកំណត់ដូចខាងក្រោមនេះ :

សរុបចំណូលថវិកា.................................១៣៩.៦០០ លានរៀល

-សរុបចំណូលចរន្ត.................................១៣៩.៦០០ លានរៀល

+ ចំណូលសារពើពន្ធ.................................៧៣.០០០ លានរៀល

+ ចំណូលមិនមែនសារពើពន្ធ.................................១៩.៦០០ លានរៀល

+ ចំណូលឧបត្ថម្ភពីថវិការដ្ឋ.................................៤៧.០០០ លានរៀល

-ចំណូលជាមូលធន.................................0 លានរៀល

+ ចំណូលជាមូលធនផ្ទៃក្នុង.................................0 លានរៀល

+ ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ.................................0 លានរៀល

សរុបចំណាយថវិកា.................................១៣៩.៦០០ លានរៀល

-ចំណាយចរន្ត.................................១៣៩.៦០០ លានរៀល

-ចំណាយជាមូលធន.................................0 លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្តក្រុងនីមួយៗក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកានេះជាជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

ជំពូកទី ៦

អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ ៥ ឆ្នាំ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.០៥១២.៥៧៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ៤៩៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខី តាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ក"
ចំណូលថវិកាចរន្តរបស់រដ្ឋ

ទំព័រ១/៥

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	អនុគណនីលម្អិត	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៥	គំរោងថវិកា ឆ្នាំ ២០០៦	គំរោង២០០៦/ច្បាប់២០០៥ កើន(+) ខ្វះ(-)	ភាគរយ
				សរុបចំណូលថវិកាចរន្តរបស់រដ្ឋ (I+II)	3.168.600	3.814.125	645.525	120,37%
				I. សរុបចំណូលថវិកាចរន្តរបស់រដ្ឋ ក្នុងតុលាការ (ក+ខ)	2.418.600	2.956.325	537.725	122,23%
				ក្នុងនោះចំណូលក្នុងស្រុក	2.298.600	2.812.720	514.120	122,37%
				ក. សរុបចំណូលចរន្ត	2.282.600	2.740.720	458.120	120,07%
				ប្រភេទទី១: ពន្ធ និង អាករ	1.741.600	2.135.000	393.400	122,59%
10				**ជំពូក១០: ពន្ធលើផលមុនប្រាក់ចំណេញ និង កំរៃមុន**	166.500	204.600	38.100	122,88%
	01			ពន្ធលើប្រាក់បៀវត្ស	31.000	37.600	6.600	121,29%
	02			ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម	123.000	152.000	29.000	123,58%
		01		សហគ្រាសសាធារណៈ	13.000	15.000	2.000	115,38%
			01	សហគ្រាសមជ្ឈិម	13.000	15.000	2.000	115,38%
			02	សហគ្រាសខេត្តនានា				
		02		សហគ្រាសឯកជន	110.000	137.000	27.000	124,55%
		03		ពន្ធកាត់ទុក				
		04		ប្រាក់ចំណេញរបស់សហគ្រាសប្រេងឥន្ធនៈ				
	03			ពន្ធលើការប្រាក់បញ្ញើធនាគារ				
	04			ពន្ធលើផលទុននៃតម្លៃចលនទ្រព្យ				
	05			ពន្ធលើផលទុននៃដីធ្លី - ផ្ទះសម្បែង	12.500	15.000	2.500	120,00%
	06			ពន្ធលើតម្លៃលើសអចលនទ្រព្យ				
	07			ពន្ធលើផលទុនកសិកម្ម				
		01		សកម្មភាពព្រៃឈើ				
		02		សកម្មភាពនេសាទ				
		03		អាជីវកម្មកសិកម្មផ្សេង១ទៀត				
	08			ពន្ធដីធ្លីលើដីសល់ទំនេរ				
	20			ពន្ធផ្សេង១ទៀតលើផលទុន - ប្រាក់ចំណេញនិងកំរៃទុន				
11				**ជំពូក១១: ពន្ធលើបេតិកភ័ណ្ឌ**				
	01			ពន្ធប្រថាប់ត្រា				
		01		ពន្ធផ្ទេរមតិករវាងអ្នកនៅរស់				
		02		ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់				
12				**ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវា**	1.008.290	1.233.761	225.471	122,36%
	01			អាករលើផលរបរ: របបផ្ទៃក្នុង	8.500	10.300	1.800	121,18%
		01		សហគ្រាសសាធារណៈ				
			01	សហគ្រាសមជ្ឈិម				
			02	សហគ្រាសខេត្តនានា				
		02		សហគ្រាសឯកជន	8.500	10.300	1.800	121,18%
	02			អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង	184.800	237.000	52.200	128,25%
		01		សហគ្រាសសាធារណៈ	14.800	16.000	1.200	108,11%
		02		សហគ្រាសឯកជន	170.000	221.000	51.000	130,00%
			01	សហគ្រាសប្រេងឥន្ធនៈ				
			02	សហគ្រាសផ្សេង១				
	03			ពន្ធពិសេស				

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦

តារាង "ក"

ចំណូលថវិកាចរន្តរបស់រដ្ឋ

ទំព័រ២/៥

ឯកតា: លានរៀល

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៥	គំរោងថវិកា ឆ្នាំ ២០០៦	គំរោង២០០៦/ច្បាប់២០០៥ កើន(+) ថយ(-)	គំរោង២០០៦/ច្បាប់២០០៥ ភាគរយ
12	04			អាករពិសេសលើទំនិញមួយចំនួន និងសេវាកម្ម	347.085	419.419	72.334	120,84%
		01		របបផ្ទៃក្នុង	56.500	68.600	12.100	121,42%
		02		របបនៃការនាំចូល	290.585	350.819	60.234	120,73%
			01	សហគ្រាសប្រេងឥន្ធនៈ				
			02	សហគ្រាសផ្សេងៗ				
	05			ពន្ធសត្តឃាដ				
	06			ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ				
	07			អាករស្នាក់នៅ				
	08			អាករលើតំលៃបន្ថែម : របបនាំចូល	467.905	567.042	99.137	121,19%
		01		សហគ្រាសប្រេងឥន្ធនៈ	123.295	152.145	28.850	123,40%
		02		សហគ្រាសដទៃទៀត	344.610	414.897	70.287	120,40%
13				**ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស**	**563.110**	**692.139**	**129.029**	**122,91%**
	01			ពន្ធ និង អាករគយពីការនាំចូល	539.911	664.998	125.087	123,17%
		01		ពន្ធគយពីការនាំចូល	281.173	338.422	57.249	120,36%
		02		កំរៃយកមុនលើផលិតផលប្រេងកាត				
		03		កំរៃយកមុនលើការងារគយក្នុងការនាំចូល	25.180	29.463	4.283	117,01%
		04		ពន្ធគយលើផលិតផលប្រេងកាត	133.596	171.533	37.937	128,40%
		05		អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំ	99.962	125.580	25.618	125,63%
		06		អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់អភិវឌ្ឍន៍				#DIV/0!
		10		ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចូល				#DIV/0!
	02			អាករពីការនាំចេញ	20.205	21.345	1.140	105,64%
		01		អាករគយពីការនាំចេញ	20.205	21.345	1.140	105,64%
			01	អាករលើការនាំឈើចេញ	3.938	2.508	-1.430	63,69%
			02	អាករលើការនាំកៅស៊ូចេញ	15.742	18.193	2.451	115,57%
			03	អាករលើការនាំផលិតផលផ្សេងៗចេញ	525	644	119	122,67%
		10		ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចេញ				#DIV/0!
	03			ការផាកពិន័យរបស់គយ	2.994	5.796	2.802	193,59%
14				**ជំពូក១៤: ចំណូលសារពើពន្ធផ្សេងៗទៀត**	**3.700**	**4.500**	**800**	**121,62%**
	01			ពន្ធតែមប្រិ៍	1.700	1.700		100,00%
	04			ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ	2.000	2.800	800	140,00%
	05			អាករលើយានយន្តនាំចូលដោយផ្ទុយនិងច្បាប់				
	06			អាករព្រលានយន្តហោះ				
	10			ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា				
				ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ	541.000	605.720	64.720	111,96%
20				ជំពូក២០: ផលខុនទៃទ្រព្យសម្បត្តិរដ្ឋ	205.849	256.808	50.959	124,76%
	01			ផលទេសាទ	7.900	9.680	1.780	122,53%
	02			ផលព្រៃឈើ	33.210	33.000	-210	99,37%
	03			ផលទុនបានមកពីសហគ្រាសសាធារណៈ	130.377	171.613	41.236	131,63%
		01		ការជួលរោងចក្រសហគ្រាស	7.803	9.000	1.197	115,34%
			01	សហគ្រាសមជ្ឈិម	7.800	8.995	1.195	115,32%
		01	02	សហគ្រាសខេត្តនានា	3	5	2	166,67%

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ក"
ចំណូលថវិកាទូទៅរបស់រដ្ឋ

ទំព័រ៣/៥

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	កម្រិតគណនី	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៥	គំរោងថវិកា ឆ្នាំ ២០០៦	គំរោង២០០៦/ច្បាប់២០០៥ កើន(+) ខ្វះ(-)	ភាគរយ
20	03	02		ការបង់ប្រាក់វិលត់ឡើងវិញ				
			01	សហគ្រាសមជ្ឈិម				
			02	សហគ្រាសខេត្តនានា				
		03		ចំនួនលើសនៃទុនចល័ត				
		04		សេវាកម្មនៃការខ្ចីចងការរបស់សហគ្រាសសាធារណៈ				
		05		ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	4.650	11.403	6.753	245,23%
		06		អាកាសចរណ៍ស៊ីវិល	40.000	50.000	10.000	125,00%
		07		ផលទុននៃសកម្មភាពភាពយន្ត				
		08		ចំណូលពីសកម្មភាពទេសចរណ៍	51.045	74.640	23.595	146,22%
		09		ការលក់សំភារៈបរិក្ខា	50		-50	
		10		ការជួលសំភារៈបរិក្ខា	10	5	-5	50,00%
		11		ផលនៃការដឹកជញ្ជូនទំនិញ	14	15	1	107,14%
		12		ផលនៃប្រតិបត្តិការពាណិជ្ជកម្ម				
		13		ការផ្គត់ផ្គង់អគ្គិសនីនៅតាមខេត្តនានា		5	5	
		14		ផលទុកនៃរដ្ឋាករទឹក		15	15	
		15		មូលនិធិថែទាំផ្លូវថ្នល់				
		20		ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ	26.805	26.530	-275	98,97%
	04			កំរៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ	8.280	12 000	3.720	144,93%
		01		សម្បទានពីប្រេងកាត				
		02		សម្បទានពីរ៉ែ	1.780	2.420	640	135,96%
		10		សម្បទានផ្សេងៗទៀត	6.500	9.580	3.080	147,38%
	05			ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ				
		01		ផលនៃការជួលកន្លែងលក់ដូរក្នុងទីផ្សារ				
		02		ពន្ធចំណតរថយន្ត				
		03		ពន្ធកំពង់ចំលង				
		04		ពន្ធកន្លែងលក់ដោយការដេញថ្លៃ				
	06			ការជួលអចលនៈវត្ថុ	25.632	29.000	3.368	113,14%
	07			ផលពីការលក់ផ្ទៃកសិកម្ម	400	965	565	241,25%
	08			ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី				
	09			ផលពីការលក់ចលនៈវត្ថុខូចខាតរបស់រដ្ឋ	50	505	455	1010,00%
	20			ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ		45	45	
21				**ជំពូក២១: ចំណូលផ្សេងៗទៀតមិនមែនសារពើពន្ធ**	**335.151**	**348.912**	**13.761**	**104,11%**
	01			ផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍	135.750	120.000	-15.750	88,40%
	02			ផលទុនវិទ្យុ ទូរទស្សន៍ ការផ្សាយ	670	1.265	595	188,81%
	03			ចំណូលនៃសេវាកម្មសាធារណៈ	197.946	224.548	26.602	113,44%
		01		កំរៃនៃការថែទាំ	215	295	80	137,21%
		02		ការលក់សំភារៈសិក្សា				
		03		ចំណូលពីមន្ទីរពេទ្យ	83.570	103.400	19.830	123,73%
		04		ផលទុននៃសកម្មភាពវប្បធម៌	650	1.395	745	214,62%
		05		ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ	165		-165	
		06		ការត្រួតពិនិត្យគុណភាពផលិតផល	12.110	17.080	4.970	141,04%

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ក"
ចំណូលថវិកាចរន្តរបស់រដ្ឋ

ទំព័រ៤/៥

ឯកតា: លានរៀល

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៥	គំរោងថវិកា ឆ្នាំ ២០០៦	គំរោង២០០៦/ច្បាប់២០០៥ កើន(+) ថយ(-)	គំរោង២០០៦/ច្បាប់២០០៥ ភាគរយ
21	03	07		ពន្ធលើការបង្កើតសហគ្រាស	250	400	150	160,00%
		08		ការបង់ប្រាក់ធានាសំរាប់បង្កើតសហគ្រាស				
		09		ការលក់ឯកសារគយ				#DIV/0!
		10		លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗរបស់គយ	3.000	4.480	1.480	149,33%
		11		ឯកសារផ្សេងៗទៀត	405	295	-110	72,84%
		12		ការលក់ឯកសារ និង លិខិតបោះពុម្ពរបស់ពន្ធដារ	1.500	2.375	875	158,33%
		13		ផលនៃការលក់ផ្លាកលេខ	901	1.650	749	183,13%
		14		ពន្ធលើការធ្វើអត្តសញ្ញាណប័ណ្ណជាតិ				
		15		អាករចុះបញ្ជីគណៈបក្សនយោបាយ				
		16		ចំណូលពីឆ្នោត	1.400	3.088	1.688	220,57%
		17		កំរៃកូតាចំពោះផលិតផលវាយនភ័ណ្ឌនាំចេញ	50.000	35.000	-15.000	70,00%
			01	ដេញថ្លៃកូតា				
			02	អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់	50.000	35.000	-15.000	70,00%
		18		ចំណូលពីកាស៊ីណូ	40.880	50.000	9.120	122,31%
		19		សេវាកម្មស៊ីរិយោដី	1.200	2.300	1.100	191,67%
		30		ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ	1.700	2.790	1.090	164,12%
	04			ប្រាក់ចំណេញរតនាគារ និង ការប្រាក់ផ្សេងៗ				
	05			ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា				
	06			ប្រាក់ចំណេញធនាគារជាតិ				
	07			ចំណូលពីអតិរេកនៃថវិកាខេត្ត ក្រុង				
	20			ចំណូលផ្សេងៗក្រៅពីសារពើពន្ធ	785	3.099	2.314	394,78%
				ខ. សរុបចំណូលជាមូលធន	**136.000**	**215.605**	**79.605**	**158,53%**
				ប្រភេទទី៣: ចំណូលជាមូលធន	136.000	215.605	79.605	158,53%
30				**ជំពូក៣០: ចំណូលផ្ទេរក្នុងជាមូលធន**	**16.000**	72.000	56.000	450,00%
	01			ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ				
	02			ការលក់ដីធ្លី				
	03			ការលក់ទ្រព្យសកម្មអរូបីយ និង ហិរញ្ញវត្ថុ				
	04			ផលឯកជនភាវូបនីយកម្ម		40.000	40.000	
	15			ចំណូលពីការខ្ចីបុលក្នុងប្រទេស	16.000	32.000	16.000	200,00%
31				**ជំពូក៣១: អំណោយពីបរទេស**	**60.000**	**66.778**	**6.778**	**111,30%**
	01			ជំនួយមនុស្សធម៌				
		01		....				
		02		....				
	02			មូលនិធិបងិភាគ	60.000	66.778	6.778	111,30%
		01		ជប៉ុន	60.000	66.778	6.778	111,30%
		02		អាល្លឺម៉ង់				
		03		បែលហ្ស៊ិក				
		04		ចក្រភពអង់គ្លេស				
		05		បារាំង				
		06		អង្គការសហប្រជាជាតិ				
		07		អ៊ីតាលី				
		08		ស៊ុយអែដ				
		30		ផ្សេងៗទៀត				

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ក"
ចំណូលថវិកាទូទៅរបស់រដ្ឋ

ទំព័រ៥/៥

ឯកតា: លានរៀល

ជំពូក	គណនី	កថាខណ្ឌ	អនុកថាខណ្ឌ	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៥	គំរោងថវិកា ឆ្នាំ ២០០៦	គំរោង២០០៦/ច្បាប់២០០៥	
							កើន(+) ថយ(-)	ភាគរយ
31	04			អំណោយដោយឡែកសំរាប់រំលស់បំណុល				
32				**ប្រភពទុនខ្ចីថ្ងៃក្នុង**	60.000	76.827	16.827	128,05%
	02			ប្រភពទុនខ្ចីពីបរទេស	60.000	76.827	16.827	128,05%
		01		ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា	60.000	76.827	16.827	128,05%
			01	ធនាគារពិភពលោក -មូលនិធិបដិភាគ				
			02	ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ -មូលនិធិបដិភាគ	60.000	76.827	16.827	128,05%
			03	....				
II. សរុបចំណូលថវិកាអនុវត្តក្រៅរតនាគារជាតិ					750.000	857.800	107.800	114,37%
សរុបចំណូលជាមូលធន					750.000	857.800	107.800	114,37%
				ប្រភេទទី៣: ចំណូលជាមូលធន	750.000	857.800	107.800	114,37%
31				**ជំពូក៣១: អំណោយពីបរទេស**	400.000	457.500	57.500	114,38%
	03			អំណោយផ្សេងៗទៀតពីបរទេស	400.000	457.500	57.500	114,38%
		01		ជប៉ុន		42.000	42.000	
		02		សហរដ្ឋអាមេរិក				
		03		អង្គការសហប្រជាជាតិ				
		04		បារាំង				
		05		អូស្ត្រាលី				
		06		ស៊ុយអែដ				
		07		ចក្រភពអង់គ្លេស				
		08		អាល្លឺម៉ង់				
		09		សហគមន៍អឺរ៉ុប				
		10		ចិន				
		11		ដាណឺម៉ាក់				
		12		ហុល្លង់				
		30		ផ្សេងៗទៀត		415.500	415.500	
32				**ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល**	350.000	400.300	50.300	114,37%
	02			ប្រភពទុនខ្ចីពីបរទេស	350.000	400.300	50.300	114,37%
		01		ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា	350.000	400.300	50.300	114,37%
			01	ធនាគារពិភពលោក -គំរោងខ្ចី	150.000	171.560	21.560	114,37%
			02	ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ -គំរោងខ្ចី	200.000	228.740	28.740	114,37%

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ខ"
ចំណាយថវិកាទូទៅរបស់រដ្ឋ

ទំព័រ១/៣
ឯកតា: លានរៀល

ក្រសួង ស្ថាប័ននានា	សរុបរួម នៃចំណាយ	សរុប ចំណាយថវរដ្ឋ	ប្រភេទទី១	ប្រភេទទី២	ប្រភេទទី៣	ប្រភេទទី៤	ប្រភេទទី៥
			មធ្យោបាយសេវា	ការប្រាក់នៃការខ្ចី	អន្តរាគមន៍សាធារណៈ	ចំណាយផ្សេងៗនិងមិនបានគ្រោងទុក	សរុបចំណាយជាមូលធន
សរុបរួមចំណាយ	**3.814.125**	**2.414.255**	**1.860.976**	**50.000**	**203.739**	**299.540**	**1.399.870**
សរុបរដ្ឋបាលកណ្តាល	***3.250.290***	***1.850.420***	***1.417.179***	***50.000***	***83.701***	***299.540***	***1.399.870***
សរុបខេត្ត-ក្រុង	***563.835***	***563.835***	***443.797***		***120.038***		
០១. ព្រះបរមរាជវាំង	**37.033**	**37.033**	**16.983**		**20.050**		
០២. រដ្ឋសភា	**47.604**	**47.604**	**44.270**		**3.334**		
០៣. ព្រឹទ្ធសភា	**20.260**	**20.260**	**18.305**		**1.955**		
០៤. ក្រុមប្រឹក្សាធម្មនុញ្ញ	**3.470**	**3.470**	**3.340**		**130**		
០៥. គណៈរដ្ឋមន្ត្រី	**77.931**	**77.931**	**64.434**		**13.497**		
១. ទីស្តីការគណៈរដ្ឋមន្ត្រី	63.517	63.517	50.517		13.000		
២. រដ្ឋ.ដ្ឋានមុខងារសាធារណៈ	1.517	1.517	1.510		7		
៣. រដ្ឋ.ដ្ឋានអាកាសចរស៊ីវិល	8.960	8.960	8.480		480		
៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	3.937	3.937	3.927		10		
០៦. ក្រសួងការពារជាតិ	**311.360**	**311.360**	**302.360**		**9.000**		
០៧. ក្រសួងមហាផ្ទៃ	**196.370**	**196.370**	**186.370**		**10.000**		
១. សន្តិសុខសាធារណៈ	176.500	176.500	168.050		8.450		
២. រដ្ឋបាលទូទៅ	19.870	19.870	18.320		1.550		
៥. សាលាខេត្ត-ក្រុងនានា							
០៨. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច	**5.364**	**5.364**	**5.324**		**40**		
១. ក្រសួង	3.739	3.739	3.719		20		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	1.625	1.625	1.605		20		
០៩. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	**58.400**	**58.400**	**57.750**		**650**		
១០. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	**38.838**	**38.838**	**33.434**		**5.404**		
១. ក្រសួង	33.428	33.428	28.151		5.277		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	5.410	5.410	5.283		127		
១១. ក្រសួងពត៌មាន	**16.606**	**16.606**	**16.457**		**149**		
១. ក្រសួង	12.981	12.981	12.910		71		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	3.625	3.625	3.547		78		
១២. ក្រសួងសុខាភិបាល	**260.973**	**260.973**	**259.616**		**1.357**		
១. ក្រសួង	176.657	176.657	176.507		150		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	84.316	84.316	83.109		1.207		
១៣. ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	**9.124**	**9.124**	**7.902**		**1.222**		
១. ក្រសួង	4.420	4.420	4.061		359		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	4.704	4.704	3.841		863		

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ខ"
ចំណាយថវិកាចរន្តរបស់រដ្ឋ

ទំព័រ២/៣

ឯកតា: លានរៀល

ក្រសួង ស្ថាប័ននានា	សរុបរួម នៃចំណាយ	សរុប ចំណាយចរន្ត	ប្រភេទទី១	ប្រភេទទី២	ប្រភេទទី៣	ប្រភេទទី៤	ប្រភេទទី៥
			មធ្យោបាយសេវា	ការប្រាក់នៃការខ្ចី	អន្តរាគមន៍សាធារណៈ	ចំណាយផ្សេងៗនិងមិនបានគ្រោងទុក	សរុបចំណាយជាមូលធន
១៤. ក្រសួងផែនការ	**7.337**	**7.337**	**7.147**		**190**		
១. ក្រសួង	4.030	4.030	3.943		87		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	3.307	3.307	3.204		103		
១៥. ក្រសួងពាណិជ្ជកម្ម	**21.484**	**21.484**	**15.314**		**6.170**		
១. ក្រសួង	18.398	18.398	12.313		6.085		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	3.086	3.086	3.001		85		
១៦. ក្រសួងអប់រំ យុវជន និង កីឡា	**442.000**	**442.000**	**431.268**		**10.732**		
១. អប់រំ	148.636	148.636	147.714		922		
២. ឧត្តមសិក្សា	16.115	16.115	15.725		390		
៣. យុវជន និង កីឡា	13.914	13.914	12.074		1.840		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	263.335	263.335	255.755		7.580		
១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	**56.819**	**56.819**	**51.199**		**5.620**		
១. ក្រសួង	36.766	36.766	35.516		1.250		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	20.053	20.053	15.683		4.370		
១៨. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ	**15.669**	**15.669**	**15.394**		**275**		
១. ក្រសួង	10.864	10.864	10.710		154		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	4.805	4.805	4.684		121		
១៩. ក្រសួងបរិស្ថាន	**9.393**	**9.393**	**9.134**		**259**		
១. ក្រសួង	6.412	6.412	6.225		187		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	2.981	2.981	2.909		72		
២០. ក្រសួងអភិវឌ្ឍន៍ជនបទ	**33.206**	**33.206**	**32.913**		**293**		
១. ក្រសួង	20.516	20.516	20.446		70		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	12.690	12.690	12.467		223		
២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	**110.849**	**110.849**	**10.569**		**100.280**		
១. ក្រសួង	6.099	6.099	4.819		1.280		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	104.750	104.750	5.750		99.000		
២២. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍	**33.438**	**33.438**	**32.463**		**975**		
១. ក្រសួង	30.933	30.933	30.020		913		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	2.505	2.505	2.443		62		
២៣. ក្រសួងធម្មការ និងកិច្ចការសាសនា	**5.754**	**5.754**	**5.609**		**145**		
១. ក្រសួង	2.767	2.767	2.753		14		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	2.987	2.987	2.856		131		
២៤. ក្រសួងកិច្ចការនារី	**13.442**	**13.442**	**9.242**		**4.200**		
១. ក្រសួង	7.678	7.678	4.678		3.000		
៤. មន្ទីរជំនាញខេត្ត-ក្រុងនានា	5.764	5.764	4.564		1.200		

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "ខ"
ចំណាយថវិកាចរន្តរបស់រដ្ឋ

ទំព័រ៣/៣
ឯកតា: លានរៀល

ក្រសួង ស្ថាប័ននានា	សរុបរួម នៃចំណាយ	សរុប ចំណាយចរន្ត	ប្រភេទទី១ មធ្យោបាយសេវា	ប្រភេទទី២ ការប្រាក់នៃការខ្ចី	ប្រភេទទី៣ អន្តរាគមន៍សាធារណៈ	ប្រភេទទី៤ ចំណាយផ្សេងៗនិងមិនបានគ្រោងទុក	ប្រភេទទី៥ សរុបចំណាយជាមូលធន
២៥. ក្រសួងសាធារណការ និង ដឹកជញ្ជូន	18.478	18.478	16.598		1.880		
១. ក្រសួង	8.668	8.668	7.068		1.600		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	9.810	9.810	9.530		280		
២៦. ក្រសួងយុត្តិធម៌	14.449	14.449	14.109		340		
១. ក្រសួង	2.982	2.982	2.922		60		
២. តុលាការកំពូល	1.230	1.230	1.215		15		
៣. សាលាឧទ្ធរណ៍	1.268	1.268	1.258		10		
៤. ក្រុមប្រឹក្សាអង្គចៅក្រម	855	855	850		5		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	8.114	8.114	7.864		250		
២៧. ក្រសួងទេសចរណ៍	17.390	17.390	16.905		485		
១. ក្រសួង	14.025	14.025	13.600		425		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	3.365	3.365	3.305		60		
២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់	12.995	12.995	12.762		233		
១. ក្រសួង	8.248	8.248	8.138		110		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	4.747	4.747	4.624		123		
២៩. ក្រសួងធនធានទឹក និង ឧតុនិយម	20.207	20.207	16.323		3.884		
១. ក្រសួង	13.171	13.171	13.050		121		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	7.036	7.036	3.273		3.763		
៣០. គជប	5.495	5.495	5.490		5		
៣១. អាជ្ញាធរសវនកម្មជាតិ	5.381	5.381	5.366		15		
៣២. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ	20.982	20.982	20.012		970		
១. ក្រសួង	16.162	16.162	15.512		650		
៥. មន្ទីរជំនាញខេត្ត-ក្រុងនានា	4.820	4.820	4.500		320		
៩៩. ចំណាយមិនទាន់បែងចែក	1.866.024	466.154	116.614	50.000		299.540	1.399.870
- ប្រាក់ឧបត្ថម្ភខេត្ត ក្រុង (ជ.១២)	47.000	47.000	47.000				
- ប្រាក់ឧបត្ថម្ភឃុំ សង្កាត់ (ជ.១២)	69.614	69.614	69.614				
- ការប្រាក់ នៃការខ្ចី (ជ.២០)	50.000	50.000		50.000			
- ចំណាយផ្សេងៗ (ជ.៤០)	267.540	267.540				267.540	
- ចំណាយមិនបានគ្រោងទុក (ជ.៤១)	32.000	32.000				32.000	
- វិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស (ជ.៥០)	445.980						445.980
- វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ (ជ.៥១)	857.800						857.800
- ការរំលស់បំណុល (ជ.៥៣)	96.090						96.090

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "គ១"
ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ
ឥណទាននៃកម្មវិធី

ទំព័រ១/៨

ឯកតាគិត : ពាន់ដុល្លារអាមេរិក

ក្រសួង ស្ថាប័ន	លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ចំណាយមុនឆ្នាំ ២០០៦ (2)	ចំណាយមុនឆ្នាំ ២០០៦ (3)	កំរិតទុនវិនិយោគចែកតាមឆ្នាំ 2006	2007	2008	សរុប៣ឆ្នាំ	ទុនសល់សំរាប់ពេលក្រោយ
		រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ								
		រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល								
	423	ព្រលានយន្តហោះខេត្តរតនគីរី	6.112,0	888	1.182	2.512	1.530	-	4.042	-
	424	ព្រលានយន្តហោះខេត្តស្ទឹងត្រែង	2.839,0	415	549	1.165	710	-	1.875	-
	420	ព្រលានយន្តហោះខេត្តមណ្ឌលគីរី	7.500,0	-	-	1.000	1.500	1.820	4.320	3.180
		សរុប	**16.451,0**	**1.303**	**1.731**	**4.677**	**3.740**	**1.820**	**10.237**	**3.180**
		ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា								
	890	គំរោងកាត់បន្ថយភាពក្រីក្រនៅជនបទ	19.620,0	2.697	3.328	5.000	1.000	3.000	9.000	4.595
		សរុប	**19.620,0**	**2.697**	**3.328**	**5.000**	**1.000**	**3.000**	**9.000**	**4.595**
		មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា								
		ក្រសួងមហាផ្ទៃ								
	731	សាងសង់សាលាឃុំ-សង្កាត់	22.700,0	-	-	1.500	-	-	1.500	21.200
	730	សាងសង់ប៉ុស្តិ៍រដ្ឋបាលរបស់ប៉ូលីស	20.000,0	-	-	1.000	-	-	1.000	19.000
	598	សាងសង់សាលាខេត្តខេត្ត-សាលាស្រុក	10.000,0	-	-	250	250	700	1.200	8.800
	599	សាងសង់និវេសនដ្ឋានសំរាប់អភិបាលខេត្ត	18.900,0	-	-	400	400	400	1.200	17.700
	603	អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធតំបន់ព្រំដែន	76.000,0	-	-	500	500	500	1.500	74.500
	506	កែទំរង់រដ្ឋបាល	22.500,0	-	-	500	500	500	1.500	21.000
		សរុប	**170.100,0**	**-**	**-**	**4.150**	**1.650**	**2.100**	**7.900**	**162.200**
		ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច								
	740	ពង្រឹងគុណភាពការងារអធិការកិច្ច	1.332,0	-	-	444	444	444	1.332	-
		សរុប	**1.332,0**	**-**	**-**	**444**	**444**	**444**	**1.332**	**-**
		ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ								
	281	ស្តារសេវាកម្មពន្ធដារតាមខេត្ត	4.106,0	-	-	1.000	500	500	2.000	2.106
	280	ស្តារសេវាកម្មគយតាមខេត្ត	42.226,0	-	-	1.000	500	500	2.000	40.226
		សរុប	**46.332,0**	**-**	**-**	**2.000**	**1.000**	**1.000**	**4.000**	**42.332**
		ក្រសួងព័ត៌មាន								
	358	បង្កើតសមត្ថភាព និងឧបករណ៍ផ្សព្វផ្សាយ	14.206,0	10.331	625	625	1.000	1.625	3.250	-
	96	ជួសជុលទីស្តីការក្រសួង	3.500,0	-	-	1.500	500	500	2.500	1.000
	416	ការបង្កើតទំនាក់ទំនងរួម ផ្ទៃគពតិមានប្រទេសអាស៊ាន	10.000,0	-	-	1.000	1.000	2.000	4.000	6.000
	334	លើកកំពស់ស្ថានីយ៍ទូរទស្សន៍	6.500,0	-	-	-	1.000	1.000	2.000	4.500
	99	ផ្សាយអភិវឌ្ឍន៍តំបន់ដាច់ស្រយាល	11.450,0	3.450	-	2.000	1.000	2.000	5.000	3.000
		សរុប	**45.656,0**	**13.781**	**625**	**5.125**	**4.500**	**7.125**	**16.750**	**14.500**
		ក្រសួងសុខាភិបាល								
	426	ត្រួតពិនិត្យគ្រប់គ្រងចំណីអាហារ និងថ្នាំសង្កូវ	8.699,0	2.024	318	656	600	259	1.515	4.842
	79	សុខភាពស្ត្រី និងកុមារ	57.074,0	51.397	1.171	1.394	1.518	1.594	4.506	-
	82	កម្មវិធីប្រយុទ្ធនឹងជំងឺរបេង	105.000,0	30.967	6.497	4.392	4.869	4.000	13.261	54.285
	83	ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់គ្រុនឈាម	47.901,0	22.905	4.779	4.500	4.500	4.500	13.500	6.717
	84	កែទំរង់ការចែកចាយឱសថស្ថាន និងសំភារៈបរិក្ខាពេទ្យ	366.915,0	56.585	248.410	20.791	20.871	20.258	61.920	-
	86	កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគ	58.811,0	22.849	7.700	6.500	7.000	8.000	21.500	6.762
	87	ការស្តារមន្ទីរពេទ្យជាតិ	143.181,0	97.145	13.704	6.155	10.787	11.324	28.266	4.066
	92	ការថែរក្សាភ្នែក ច្រមុះ ធ្មេញ	8.155,0	4.547	1.013	500	500	500	1.500	1.095
	78	ពង្រឹងសេវាសុខាភិបាលមូលដ្ឋាន	508.821,0	336.133	43.688	37.000	40.000	52.000	129.000	-
	962	គំរោងគ្រប់គ្រងជំងឺកុមារ	5.567,0	420	1.076	500	500	500	1.500	2.571

សំគាល់: តំលៃបាន់ស្មានពីក្រសួង-ស្ថាប័ននានា។ ប្រភពពត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦

តារាង "គ១"

ចំណាយជាមូលធននៃថវិកាចរន្តរបស់រដ្ឋ

ឥណទាននៃកម្មវិធី

ទំព័រ២/៧

ឯកតាគិត : ពាន់ដុល្លារអាមេរិក

ក្រសួង ស្ថាប័ន	លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ចំណាយមុនឆ្នាំ ២០០៦		កិច្ចសន្យាវិនិយោគចែកតាមឆ្នាំ				ខ្ទង់សល់សំរាប់ពេលក្រោយ
				(2)	(3)	2006	2007	2008	សរុប៣ឆ្នាំ	
	701	អភិវឌ្ឍន៍ឱសថបូរាណ	4.935,0	2.130	905	600	700	600	1.900	-
	886	លើកកំពស់គ្រូពេទ្យ ឆ្មប បំពងក	4.149,0	467	278	318	364	418	1.100	2.304
		សរុប	**1.319.208,0**	**627.569**	**329.539**	**83.306**	**92.199**	**103.953**	**279.458**	**82.642**
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល										
	828	គំរោងពង្រីកអានុភាពផលិតថាមពលអគ្គិសនី ១០ មេកាវ៉ាត់	15.000,0	-	1.400	2.100	5.000	6.500	13.600	-
	769	គំរោងវារីអគ្គិសនីខ្នាតតូចសំរាប់អគ្គិសនីការូបនីយកម្មជនបទ	4.800,0	-	-	1.000	1.000	571	2.571	2.229
	556	សាងសង់បណ្តាញបញ្ជូននិងការូបនីយកម្ម អគ្គិសនីជនបទ	70.000,0	-	-	1.000	500	500	2.000	68.000
	902	គំរោងសាងសង់ខ្សែបញ្ជូនតង់ស្យុង ២៣០ មេកាវ៉ាត់ កំពត កំពង់សោម '	26.000,0	-	-	2.000	1.000	1.000	4.000	22.000
	899	សិក្សានិងសាងសង់វារីអគ្គិសនីសៀមរាប	8.000,0	-	-	2.000	1.000	1.200	4.200	3.800
	903	សាងសង់ខ្សែបញ្ជូនថាមពលតង់ស្យុងខ្ពស់(តាកែវ-កំពត)	18.000,0	-	-	1.100	2.100	1.000	4.200	13.800
	455	ការបង្កើតវិទ្យាស្ថានជាតិផលិតភាពនៃកម្ពុជា	1.100,0	-	-	300	550	250	1.100	-
	999	គំរោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទីប្រជុំជនខេត្ត និងក្រុង	15.094,0	724	2.245	5.045	5.545	1.535	12.125	-
	673	គំរោងអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹកស្អាតនៅខេត្តព្រៃវែង	8.717,0	-	-	1.825	2.000	2.000	5.825	2.892
		សរុប	**166.711,0**	**724**	**3.645**	**16.370**	**18.695**	**14.556**	**49.621**	**112.721**
ក្រសួងផែនការ										
ក្រសួងពាណិជ្ជកម្ម										
	344	មជ្ឈមណ្ឌលអភិវឌ្ឍន៍ពាណិជ្ជកម្ម	25.500,0	-	-	8.000	-	-	8.000	17.500
	6	មន្ទីរពិសោធន៍ពិនិត្យគុណភាពផលិតផល	5.396,0	-	-	1.000	1.000	1.000	3.000	2.396
	681	សាងសង់អាគាររដ្ឋបាល	600,0	-	-	600	-	-	600	-
		សរុប	**31.496,0**	**-**	**-**	**9.600**	**1.000**	**1.000**	**11.600**	**19.896**
ក្រសួងអប់រំ យុវជន និង កីឡា										
	876	ការអប់រំមូលដ្ឋាននិងបណ្តុះបណ្តាលគ្រូបង្រៀន	14.106,0	3.526	3.526	3.527	2.527	-	6.054	1.000
	722	ការផ្គត់ផ្គង់សំភារៈសិក្សាសំខាន់ៗ	34.396,0	10.480	3.375	2.450	3.425	4.625	10.500	10.041
	736	លើកកំពស់ការឡើងថ្នាក់អប់រំបឋម	58.093,0	23.755	9.650	5.500	8.000	10.500	24.000	688
	797	ការបំពេញការងារប្រកបដោយប្រសិទ្ធិភាពនៃសេវាអប់រំ	26.113,0	6.075	4.175	3.275	4.375	5.800	13.450	2.413
	735	ពង្រឹងគុណភាពនៅឧត្តមសិក្សា	7.009,0	2.145	489	1.375	1.500	1.500	4.375	-
	719	កម្មវិធីអភិវឌ្ឍន៍សំភារៈសិក្សា	168.000,0	72.850	20.000	18.750	15.500	19.000	53.250	21.900
	721	ពង្រឹងគុណភាពនៅមធ្យមសិក្សា	10.341,0	5.000	925	1.200	1.425	1.750	4.375	41
		សរុប	**318.058,0**	**123.831**	**42.140**	**36.077**	**36.752**	**43.175**	**116.004**	**36.083**
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ										
	315	ការរានដីដែលបោះបង់ចោល	5.875,0	-	-	895	229	226	1.350	4.525
	501	ជួសជុលរចនាសម្ព័ន្ធស្ថានីយ៍គោកត្រប់ និងព្រៃផ្តៅ	194,0	-	-	72	122	-	194	-
	913	កែច្នៃផលិតផលកសិកម្ម	843,0	-	-	326	276	241	843	-
	694	វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម	2.000,0	-	-	700	800	500	2.000	-
	751	ផ្សព្វផ្សាយបច្ចេកវិទ្យាគ្រឿងយន្តកសិកម្ម	1.305,0	-	-	340	284	256	880	425
	175	លើកកំពស់ស្ថានីយ៍ស្រាវជ្រាវ	1.390,0	-	-	577	467	242	1.286	104
	275	ជួសជុល-សាងសង់អគារគ្រឿងយន្តកសិកម្ម	772,0	-	-	264	254	254	772	-
	216	កែលំអវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា	2.700,0	-	-	1.900	800	-	2.700	-
	174	សាងសង់អាគារបំរើឱ្យវិស័យកសិកម្ម	2.210,0	-	-	810	700	700	2.210	-
	144	ស្រាវជ្រាវកសិផល និងផលិតផលគ្រាប់ពូជ	500,0	-	-	164	164	172	500	-
	906	បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសាកវប្បកម្ម	3.110,0	-	-	611	907	1.592	3.110	-
	161	ពង្រឹងមជ្ឈមណ្ឌលបង្កាត់គោពូជ	6.145,0	-	-	1.000	1.000	1.000	3.000	3.145
	630	ផលិតវ៉ាក់សាំង	400,0	-	-	322	39	39	400	-
	521	ស្ថានីយ៍បង្កាត់ពូជគោដោយសិប្បនិម្មិត	91,0	-	-	33	58	-	91	-

សំគាល់: តំលៃប៉ាន់ស្មានពីក្រសួង-ស្ថាប័ននានា ។ ប្រភពពត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ: ក្រសួងផែនការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "គ១"
ចំណាយជាមូលធនដែលជាមូលធននៃធនធានក្នុងស្រុកវិនិយោគរបស់រដ្ឋ
តាមគំរោងនៃកម្មវិធី

ទំព័រ៣/៧

ឯកតាគិត : ពាន់ដុល្លារអាមេរិក

ក្រសួង ស្ថាប័ន	លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ចំណាយមុនឆ្នាំ ២០០៦ (2)	(3)	ការគិតគូរវិនិយោគចែកតាមឆ្នាំ 2006	2007	2008	សរុប3ឆ្នាំ	ខ្ទង់សល់សំរាប់ពេលក្រោយ
	523	បង្កើតស្ថានីយ៍ស្រាវជ្រាវវារីវប្បកម្មសមុទ្រ	8.000,0	-	-	3.000	3.000	2.000	8.000	-
	524	ទឹកឆា ស្ថានីយ៍ស្រាវជ្រាវវារីវប្បកម្មទឹកសាប	10.535,0	-	-	2.000	2.000	2.000	6.000	4.535
	514	អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផល	13.561,0	-	-	4.000	4.561	5.000	13.561	-
	771	ការគ្រប់គ្រងព្រៃឈើអាងទន្លេមេគង្គ	1.610,0	-	-	700	540	370	1.610	-
	328	គំរោងគ្រប់គ្រងព្រៃព្រែកទឹកសាប	14.600,0	-	-	550	500	500	1.550	13.050
	907	ការបង្ក្រាបការរុករានទន្ទ្រានព្រៃឈើ	10.000,0	-	-	1.000	1.000	1.000	3.000	7.000
	988	គំរោងដាំឈើ និងដាំឈើឡើងវិញចំនួន ២.០០០ ហត	1.474,0	-	-	548	490	436	1.474	-
	822	ជួសជុលស្ថានីយ៍ពិសោធន៍កសិកម្មនិងមណ្ឌលអភិវឌ្ឍន៍កសិកម្ម	1.286,0	-	-	577	467	242	1.286	-
	750	ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអប់រំនៅសកលវិទ្យា ល័យភូមិន្ទកសិកម្ម	13.100,0	-	-	2.305	3.390	7.405	13.100	-
	619	ជួសជុលមជ្ឈមណ្ឌលបច្ចេកទេសកសិកម្មទួលសំរោង	16.500,0	-	-	500	500	1.000	2.000	14.500
	520	ជួសជុលសាលាកសិកម្មកំពង់ចាម	10.414,0	-	-	2.000	2.500	3.104	7.604	2.810
	330	ជួសជុលកែលំអ អាគារក្សេត្រសាស្ត្រ	312,0	-	-	312	-	-	312	-
	302	សាងសង់ជួសជុលអាគារមន្ទីរកសិកម្មខេត្តក្រុង	2.112,0	-	-	288	288	288	864	1.248
	502	សំណង់ទំនប់ការពារទឹកជំនន់	396,0	-	-	88	308	-	396	-
	684	ផ្តល់អាហារូបត្ថម្ភសំរាប់មាតា និងកុមារ	623,0	-	-	277	224	122	623	-
	329	ស្ថាបនាមូលដ្ឋានអភិរក្សសត្វព្រៃនៅឧទ្យានភ្នំតាម៉ៅ	426,0	-	-	308	59	59	426	-
		សរុប	**132.484,0**	**-**	**-**	**26.467**	**25.927**	**28.748**	**81.142**	**51.342**
ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ										
	578	ជួសជុលបណ្ណាល័យជាតិ	1.500,0	100	-	400	300	-	700	700
	217	ជួសជុលប្រាសាទបុរាណ	3.000,0	-	-	781	1.219	1.000	3.000	-
	739	ជួសជុលសំណង់ចាស់ៗនៅភ្នំព្រះរាជទ្រព្យ	7.000,0	-	-	630	1.647	1.923	4.200	2.800
	974	សាងសង់សារមន្ទីរតាមបណ្តាខេត្ត-ក្រុង	1.500,0	-	-	602	599	299	1.500	-
	973	សាងសង់ និងស្តារឡើងវិញនូវការិយាល័យធ្វើការ	800,0	-	-	270	265	265	800	-
		សរុប	**13.800,0**	**100**	**-**	**2.683**	**4.030**	**3.487**	**10.200**	**3.500**
ក្រសួងបរិស្ថាន										
	873	ការអភិរក្សជំរកសត្វព្រៃកម្ពុជា	4.305,0	655	675	950	1.000	-	1.950	1.025
	63	បង្កើតវិទ្យាស្ថានស្រាវជ្រាវ និងការគ្រប់គ្រងបំពុលបរិស្ថាន	9.714,0	-	-	500	500	500	1.500	8.214
		សរុប	**14.019,0**	**655**	**675**	**1.450**	**1.500**	**500**	**3.450**	**9.239**
ក្រសួងអភិវឌ្ឍន៍ជនបទ										
	475	អភិវឌ្ឍន៍ភូមិគំរូ	1.780,0	-	-	500	500	600	1.600	180
	297	សិក្សាវាស់វែងលេខា និងជួសជុលផ្លូវលំ 656 គ.ម	26.307,0	-	-	1.000	1.000	1.000	3.000	23.307
	430	កម្មវិធីថែទាំផ្លូវជនបទ 2237 គ.ម	18.000,0	-	-	1.000	1.500	2.000	4.500	13.500
	474	ស្តារផ្លូវជនបទ 433.1 គ.ម	4.034,0	-	-	958	1.749	1.327	4.034	-
	921	សាងសង់លូ6000 និងស្ពានបេតុង120 កន្លែង	32.400,0	-	-	1.000	1.000	1.000	3.000	29.400
	922	សាងសង់-អភិវឌ្ឍន៍ផ្លូវតំបន់ព្រំដែន	45.000,0	-	-	1.000	1.000	1.000	3.000	42.000
	943	ជួសជុលផ្លូវលំជនបទ	30.000,0	-	-	1.000	1 000	1.000	3.000	27 000
	196	ផ្គត់ផ្គង់អគ្គិសនីជនបទដោយពន្លឺព្រះអាទិត្យ	5.171,0	-	-	1.195	705	1.000	2.900	2 271
	274	សាងសង់វារីអគ្គិសនីនៅមណ្ឌលគិរី	3.100,0	-	-	1.450	1 650	-	3.100	-
	363	ជីកអណ្តូងចំនួន 113	344,0	-	-	167	177	-	344	-
	362	ជួសជុល និងសាងសង់បន្ថែមប្រព័ន្ធស្រោចស្រព	1.300,0	-	-	236	483	581	1 300	-
	361	សាងសង់ប្រព័ន្ធស្រោចស្រព 400ហិកតា	5.172,0	-	-	1 195	1.705	2.272	5.172	-
	364	សិក្សាវាស់វែងលេខាប្រព័ន្ធស្រោចស្រព ១០០ហិកតា	82,0	-	-	82	-	-	82	-
	192	ប្រព័ន្ធធារាសាស្ត្រតូចៗ	33.000,0	-	-	-	2.000	3.000	5.000	28.000
	301	សិក្សាវាស់វែងលេខា និងជួសជុលប្រព័ន្ធធារាសាស្ត្រ	620,0	-	-	620	-	-	620	-
	432	ជួសជុលថែរក្សាអណ្តូងស្នប់	1.960,0	-	-	644	653	663	1 960	-

សំគាល់: តំលៃចាត់ស្មានពីក្រសួង-ស្ថាប័ននានា។ ប្រភពពត៌មាន: មិន្ទីរ័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
ភាពគ "គ១"
ចំណាយជាមូលធននៃថវិកាចរន្តនៅរបស់រដ្ឋ
តំណាងនៃកម្មវិធី

ទំព័រ៤/៨

ឯកតាគិត : ពាន់ដុល្លារអាមេរិក

ក្រសួង ស្ថាប័ន	លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ចំណាយមុនឆ្នាំ ២០០៦		កំរិតទុនវិនិយោគបែងចែកតាមឆ្នាំ				ទុនសល់សំរាប់ពេលក្រោយ
				(2)	(3)	2006	2007	2008	សរុប៣ឆ្នាំ	
	429	សន្តិសុខស្បៀង អាហាររូបត្ថម្ភក្នុងសហគមន៍	1.817,0	-	-	400	400	400	1.200	617
	431	អនាម័យ និងបរិស្ថាន	882,0	-	-	294	294	294	882	-
	365	ផលិតស្បៀងជាលក្ខណៈគ្រួសារ	5.099,0	-	-	740	580	495	1.815	3.284
	210	សាងសង់អាគារមន្ទីរការិយាល័យនិងផ្នែកអភិវឌ្ឍន៍ជនបទខេត្ត-ស្រុក-ឃុំ	78.000,0	-	-	450	450	450	1.350	76.650
	70	កម្មវិធីឥណទានជនបទ	2.360,0	-	-	747	817	796	2.360	-
	209	អភិវឌ្ឍន៍អាជីវកម្មធុនតូចតាមភូមិ	1.891,0	-	-	626	632	633	1.891	-
		សរុប	**298.319,0**	**-**	**-**	**15.304**	**18.295**	**18.511**	**52.110**	**246.209**
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា										
	126	សាងសង់ និងជួសជុលបណ្ដាអធិការដ្ឋានស.ក.ប.យ. ខេត្តក្រុង	340,0	-	-	130	130	80	340	-
	961	សាងសង់អាគាររដ្ឋបាលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	198,0	-	-	121	41	36	198	-
	594	សាងសង់ភូមិសំរាប់កុមារ	8.700,0	4.200	-	1.000	1.250	1.750	4.000	500
	781	សាងសង់អាគារការិយាល័យសង្គមកិច្ចស្រុកទាំង ៥	408,0	-	-	145	145	118	408	-
	958	សង់មជ្ឈមណ្ឌលយុវនីតិសម្បទា ខេត្តកំពត	270,0	-	-	178	92	-	270	-
	959	សង់មជ្ឈមណ្ឌលយុវនីតិសម្បទា ខេត្តបាត់ដំបង	270,0	-	-	178	92	-	270	-
	960	សង់មជ្ឈមណ្ឌលយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ	270,0	-	-	178	92	-	270	-
		សរុប	**10.456,0**	**4.200**	**-**	**1.930**	**1.842**	**1.984**	**5.756**	**500**
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍										
	294	បណ្ដាញទូរគមនាគមន៍បណ្ដាខេត្តភូមិភាគកណ្ដាល	28.000,0	-	-	2.000	1.000	2.000	5.000	23.000
	400	បណ្ដាញបញ្ជូនស៊ីញ៉ាល់ ភ្នំពេញ-ព្រំដែនឡាវ	20.000,0	-	-	1.000	2.000	3.000	6.000	14.000
	295	បណ្ដាញខ្សែអុបទិក ភ្នំពេញ-កំពង់ធំ-សៀមរាប	9.000,0	-	-	1.380	2.000	3.000	6 380	2.620
	401	បណ្ដាញបញ្ជូនស៊ីញ៉ាល់ ភ្នំពេញ-ក្រុងព្រះសីហនុ	10.000,0	-	-	2 800	2.000	5.200	10.000	-
	419	អភិវឌ្ឍន៍បណ្ដាញទូរគមនាគមន៍ជនបទ	2.500,0	-	-	2.500	-	-	2.500	-
		សរុប	**69.500,0**	**-**	**-**	**9.680**	**7.000**	**13.200**	**29.880**	**39.620**
ក្រសួងធម្មការ និង សាសនា										
	558	សាងសង់អាគារធ្វើការ	2.700,0	-	-	900	900	900	2.700	-
	509	សាងសង់បណ្ណាល័យក្រសួង	1.350,0	-	-	450	450	450	1.350	-
		សរុប	**4.050,0**	**-**	**-**	**1.350**	**1.350**	**1.350**	**4.050**	**-**
ក្រសួងកិច្ចការនារី										
	614	សាងសង់ និងជួសជុលអាគាររដ្ឋបាល	29.581,0	3.834	-	13.389	11.189	5.003	29 581	(3.834)
	112	កម្មវិធីស្ត្រីក្នុងការអភិវឌ្ឍជំហានទី ១	23.327,0	7.934	2.395	1.549	880	-	2.429	10.569
		សរុប	**52.908,0**	**11.768**	**2.395**	**14.938**	**12.069**	**5.003**	**32.010**	**6.735**
ក្រសួងសាធារណការ និង ដឹកជញ្ជូន										
	802	គំរោងកែលំអផ្លូវជាតិលេខ ៤៨ ជំហ៊ាន ២	17.000,0	-	6.000	5.000	3.000	-	8.000	3 000
	695	ជួសជុលផ្លូវ៧ ក្រចេះ-ស្ទឹងត្រែង-ព្រំប្រទល់ឡាវ	50.000,0	5.000	15.000	20.000	10.000	-	30.000	-
	464	សាងសង់ស្ពានតាខ្មៅ កណ្ដាល	35.000,0	-	1.500	3.000	3 000	4.000	10.000	23.500
	461	លើកកំរិតផ្លូវជាតិលេខ៣ ត្រពាំងរពៅ-កំពត	17.500,0	-	5.000	5.000	4.500	-	9 500	3.000
	235	ជួសជុលផ្លូវជាតិលេខ 2 តាកែវ-ភ្នំដិន	11.970,0	-	5.670	500	-	-	500	5.800
	278	ស្តារឡើងវិញផ្លូវជាតិលេខ៣.៦និងផ្លូវក្រុង	49.618,0	15.818	115	500	-	-	500	33 185
	327	គំរោងអភិវឌ្ឍន៍ទីរួមខេត្ត-ក្រុង	8.600,0	2.220	1.000	500	-	-	500	4 880
	801	សាងសង់ស្ពានចំនួន ៤ តាមផ្លូវជាតិលេខ ៤៨	8.000,0	-	4.000	3.000	-	-	3.000	1 000
	854	ស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវ ខេត្ត-ជនបទ (PRIP)	16.550,0	-	4.400	2.400	-	-	2 400	9 750
	800	លើកកំរិតផ.ជ៥.៦ ស.រាប-ប៉ោយប៉ែត១៥០ Km (GMS)	77.500,0	-	3.000	7.557	10.000	10.000	27.557	46 943
	1004	ស្តារផ្លូវជាតិលេខ ៦អា លេខ ៦ និង ៧	25 000,0	-	-	5.000	10.000	10.000	25 000	-
	855	ស្តារផ្លូវជាតិលេខ267 (សៀមរាម-អន្លង់វែង-ច្រកស្រងាំ)	27.800,0	-	3.000	5.800	9.000	10.000	24.800	-

សំគាល់: តំលៃបាន់ស្មានពីក្រសួង-ស្ថាប័ននានា ។ ប្រភពពត៌មាន: ទិន្នន័យនៃកម្មវិធីវិនិយោគសាធារណៈ ក្រសួងផែនការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការគ្រប់គ្រងឆ្នាំ ២០០៦
តារាង "គ១"
ចំណាយជាមូលធននៃថវិកាទូទៅរបស់រដ្ឋ
ឥណទាននៃកម្មវិធី

ទំព័រ៤/៧

ឯកតាគិត : ពាន់ដុល្លារអាមេរិក

ក្រសួង ស្ថាប័ន	លេខគំរោង	ឈ្មោះគំរោង	តំលៃគំរោង	ចំណាយមុនឆ្នាំ ២០០៦		កិច្ចសន្យាវិនិយោគចែកតាមឆ្នាំ				ទុនសល់សំរាប់ពេលក្រោយ
				(2)	(3)	2006	2007	2008	សរុប៣ឆ្នាំ	
	799	កែលំអផ្លូវជាតិលេខ ១ ភ្នំពេញ-អ្នកលឿង	45.000,0	-	-	1.300	8.700	8.500	18.500	26.500
	696	ជួសជុលផ្លូវជាតិលេខ ៦៤ កំពង់ធំ-ព្រះវិហារ	23.550,0	-	-	700	500	500	1.700	21.850
	697	ជួសជុលផ.៥៧ បាត់ដំបង-ប៉ៃលិន-ព្រំប្រទល់ថៃ	14.550,0	-	-	2.000	2.000	3.000	7.000	7.550
	698	ជួសជុលផ.៥៧ បាត់ដំបង-ប៉ៃលិន-ព្រំប្រទល់ថៃ	31.350,0	-	-	2.000	2.000	2.000	6.000	25.350
	700	ជួសជុលផ.៧៦-១៦៩ គ.មបានលុង-តំបន់ត្រីកោណ	24.000,0	-	-	1.000	1.000	2.000	4.000	20.000
	759	សាងសង់ស្ពានអ្នកលឿង	120.000,0	-	-	4.000	5.000	7.000	16.000	104.000
	762	សាងសង់ផ្លូវជាតិលេខ 76 B	1.500,0	-	-	600	900	-	1.500	-
	237	ស្តារឡើងវិញផ្លូវជាតិលេខ៣	68.000,0	-	-	5.500	6.000	6.000	17.500	50.500
